គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

# ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២

យុវជនត្រូវបានទទួលស្គាល់ថា ជាធនធានមួយដ៏ចាំបាច់សម្រាប់កំណត់វាសនានាថ្ងៃអនាគតរបស់ប្រទេសជាតិមួយ ជាពិសេសចីរភាព និងគុណភាពនៃដំណើរការប្រជាធិបតេយ្យ ហើយកត្តាដែលនាំឱ្យយុវជនកាន់តែមានតម្លៃនយោបាយថែមទៀតនោះគឺ ក្រុមយុវជនទាំងនេះអាចមានឥទ្ធិពលដល់លទ្ធផលឆ្នោត ដែលជាបុព្វហេតុនៃការរៀបចំរដ្ឋាភិបាល និងគោលនយោបាយ។ របាយការណ៍ខាងក្រោម គឺបានមកពីការសិក្សារបស់ខុមហ្វ្រែល ទៅលើការចូលរួមរបស់យុវជនក្នុងកិច្ចការនយោបាយ និងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២កន្លងមក រួមទាំងការអនុវត្តសិទ្ធិបោះឆ្នោត និងក្រោយជាប់ឆ្នោតរបស់យុវជន។ ជាក់ស្តែងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣ ឆ្នាំ២០១២កន្លងមកនេះ អ្នកចេញទៅបោះឆ្នោតមានប្រមាណតែ ៦៤% នៃចំនួនអ្នកបោះឆ្នោតសរុប ក្នុងបញ្ជីបោះឆ្នោត ៩,២០៣,៤៩៣នាក់។ ក្នុងចំនួនអ្នកបោះឆ្នោតរាប់លាននាក់នេះ យុវជនដែលមានអាយុពី ១៨ឆ្នាំ ដល់ ៣៥ឆ្នាំ មានរហូតដល់ ៥៤%។

បើតាមទិន្នន័យជំរឿនឆ្នាំ២០០៨បានបង្ហាញថា អ្នកមានសិទ្ធិបោះឆ្នោតដែលមានអាយុក្រោម៣០ឆ្នាំ មានចំនួនប្រមាណ ៤១% នៃអ្នកមានសិទ្ធិបោះឆ្នោតសរុប។ សម្រាប់ការបោះឆ្នោត យ៉ាងហោចណាស់ មានយុវជនចុះឈ្មោះបោះឆ្នោត១,២ លាននាក់ ដែលជាអ្នកបោះឆ្នោតលើកទីមួយ។ កត្តានេះហើយបានធ្វើគណបក្សនយោបាយនានាធ្វើសកម្មភាពដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីក្រុមនេះ និងដើម្បីឲ្យពួកគេក្លាយទៅជាកម្លាំងនយោបាយក្នុងការបោះឆ្នោតគាំទ្រដល់គណបក្សខ្លួនក្នុងការបោះឆ្នោតឆ្នាំ២០១២កន្លងមក និងឆ្នាំ២០១៣ខាងមុខ។ ការសង្កេតឃើញថា គណបក្សសំខាន់ៗដែលមានអាសនៈក្នុងរដ្ឋសភា បានរៀបចំចលនា ឬរចនាសម្ព័ន្ធយុវជនគណបក្សរបស់ខ្លួន។ ជាក់ស្តែងគណបក្សប្រជាជនកម្ពុជាបានបង្កើតចលនាយុវជនប្រតិកម្មរហ័ស។ ចលនាយុវជនរបស់គណបក្សប្រជាជនកម្ពុជា មានការចូលរួមដឹកនាំដោយកូនប្រុសរបស់លោកនាយករដ្ឋមន្ត្រី និងកូនមន្ត្រីនយោបាយសំខាន់ៗរបស់គណបក្សប្រជាជនកម្ពុជា ដែលស្របតាមឋានៈឪពុកម្តាយដែលមានតួនាទីជាន់ខ្ពស់ក្នុងគណបក្សនយោបាយ និងកិច្ចការរដ្ឋ។ កូនប្រុសរបស់លោកនាយករដ្ឋមន្ត្រី និងអនុប្រធានគណបក្សប្រជាជនកម្ពុជា បានចេញមុខរៀបចំការប្រជុំ និងបណ្តុះបណ្តាលយុវជនសកម្មក្នុងគណបក្សរបស់ខ្លួនច្រើនជាងគណបក្សផ្សេងៗទៀត។ សកម្មជនជាយុវជនរបស់គណបក្សប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយ តាមរយៈទូរទស្សន៍ និងវិទ្យុយ៉ាងច្រើន តាំងពីកិច្ចការមនុស្សធម៌ដូចជាការផ្តល់ឈាម រហូតដល់ការងារអភិវឌ្ឍន៍។ គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ក៏បានបង្កើតចលនាយុវជនរបស់គណបក្សខ្លួន។ ចំណែកឯគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សនរោត្តមរណឫទ្ធិ ក៏មានបង្កើតក្រុមយុវជន និងធ្វើការបញ្ចូលពួកគេក្នុងរចនាសម្ព័ន្ធថ្នាក់ក្រោមរបស់គណបក្សខ្លួនផងដែរ។ ប៉ុន្តែរហូតមកដល់ពេលនេះនៅមិនទាន់មានសញ្ញាណអ្វីជាដុំកំភួន ឬបានចែងនៅក្នុងគោលនយោបាយគណបក្សទាំងនោះ ដោយគិតគូរអំពីផលប្រយោជន៍ និងផ្តល់ឱកាសសម្រាប់យុវជន ដើម្បីទទួលបាននូវឋានៈ និងតួនាទីសមរម្យក្នុងគណបក្សនៅឡើយ

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទស្សនៈវិស័យ ៖ ដើម្បីការបោះឆ្នោតមានសេរី និងយុត្តិធម៌ ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office** : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

ទេ ក្រៅតែពីការអូសទាញពួកគេឲ្យបោះឆ្នោតគាំទ្រគណបក្សខ្លួនប៉ុណ្ណោះ។ ទោះបីជាមិនទាន់មានតួលេខពិតប្រាកដពីចំនួនយុវជនឈរឈ្មោះបោះឆ្នោត និងយុវជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នា២០១២ តែជាក់ស្តែងយុវជនជាច្រើនបានចាប់ផ្តើមងាកមកចាប់អារម្មណ៍កិច្ចការនយោបាយ តាមរយៈការចូលរួមជាសមាជិកសកម្មរបស់គណបក្សនយោបាយ ហើយបានចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោតយ៉ាងគគ្រឹកគគ្រេង។

នៅក្នុងដំណាក់ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ខុមហ្វ្រែលបានរកឃើញថានៅមានយុវជនគ្រប់អាយុបោះឆ្នោតមួយចំនួនមិនបានទៅចុះឈ្មោះបោះឆ្នោត បើទោះជាលទ្ធផលនៃការចុះឈ្មោះរបស់ គ.ជ.ប ធ្វើបានលើសផែនការណ៍ក៏ដោយ។ មូលហេតុសំខាន់មួយចំនួនដែលក្រុមនេះមិនបានចុះឈ្មោះបោះឆ្នោតរួមមាន មិនមានឯកសារបញ្ជាក់អត្តសញ្ញាណ មិនចាប់អារម្មណ៍ និងមិនយល់ពីសារៈសំខាន់នៃការបោះឆ្នោត ខ្វះព័ត៌មាន អស់ជំនឿនឹងការបោះឆ្នោត និងចំណាកស្រុកជាដើម។ តាមការសង្កេតចំពោះឃុំ-សង្កាត់មួយចំនួនបានរកឃើញថាមានយុវជនមកចុះឈ្មោះបោះឆ្នោតដែលមានចំនួនតិចនោះរួមមាន ខេត្តកំពង់ឆ្នាំង ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តព្រះវិហារ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យជាដើម។

តាមរយៈការសិក្សាស្រាវជ្រាវដោយ ខុមហ្វ្រែល ទាក់ទិនទៅនឹងការឃោសនាបោះឆ្នោតនាពេលកន្លងមកនេះ បានសង្កេតឃើញថា សកម្មភាពឃោសនានយោបាយរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់យុវជនត្រូវបានផលិតឡើងជាលក្ខណៈកំសាន្តច្រើនជាងការផ្សព្វផ្សាយជាសារនយោបាយទៅកាន់អ្នកគាំទ្ររបស់ខ្លួន។ ការប្រើប្រាស់សម្ភារៈសម្រាប់ឃោសនាទៀតសោត មានភាពទំនើប និងទាន់សម័យ ហើយមានភាពទាក់ទាញ ដោយប្រើប្រាស់ឧបករណ៍ទំនើបៗមានដូចជា ការបិទខិត្តប័ណ្ណ ផ្ទាំងរូបភាពផ្សេងៗ ការជួបជុំក្រុមយុវជនដ៏ធំនៅថ្ងៃឃោសនា រថយន្តធំៗដឹកឆាកតន្ត្រីចល័តអមដោយអ្នករាំស្រីស្រស់ស្អាត ការបញ្ចាំងវីដេអូលើផ្ទាំងសំពត់សដើម្បីផ្សាយសារនយោបាយ និងសម្មិទ្ធិផលរបស់គណបក្សក្បួនដង្ហែររថយន្ត និងម៉ូតូដ៏វែងកាត់តាមដងផ្លូវ។ កម្មវិធីកំសាន្ត ការប្រគុំតន្ត្រី ការសម្តែងសិល្បៈ របស់អ្នកកំប្លែងជាដើមភាគច្រើនបានរៀបចំជាទ្រង់ទ្រាយធំនៅទីប្រជុំជន និងទីក្រុង។ គណបក្សប្រជាជនកម្ពុជាបានបង្ហាញយុវជនដែលជាអ្នកគាំទ្ររបស់ខ្លួនយ៉ាងច្រើនសន្ធឹកសន្ធាប់ តាមរយៈយុទ្ធនាការ និងប្រព័ន្ធផ្សព្វផ្សាយ ដោយការប្រមូលផ្តុំយុវជនមកពីបណ្តាញក្រុមការងារនៅថ្នាក់ឃុំ ស្រុក ខេត្ត រាជធានី រាប់ទាំងមន្ត្រីរាជការ សិស្ស និស្សិត និងតារាសិល្បះ។ ក្នុងគោលដៅស្វែងរកអ្នកគាំទ្រជាយុវជនដូចគ្នា គណបក្សសមរង្ស៊ី បានងាកមកចាប់យកអ្នកគាំទ្រ ជានិស្សិតមហាវិទ្យាល័យ និងយុវជនដែលជាកម្មករធ្វើការនៅរោងចក្រកាត់ដេរ ដោយសារយុវជនទាំងនោះ ចង់បានការគាំទ្រស្រាប់ពីអ្នកនយោបាយ និងរំពឹងទុកក្នុងការផ្លាស់ប្តូររបៀបដឹកនាំបច្ចុប្បន្ន។ អ្នកសកម្មជនក្នុងការឃោសនា គឺភាគច្រើនសុទ្ធតែជាយុវជន ដែលមកពីតាម វិទ្យាល័យ មហាវិទ្យាល័យ សាកលវិទ្យាល័យ និងបណ្តាញយុវជនរបស់គណបក្សរៀងខ្លួន។ ចំណែកគណបក្សប្រឆាំងបានយកចិត្តទុកដាក់នឹងខ្លឹមសារនយោបាយ ទិតៀនរាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា ដែលអាចទាក់ទាញយុវជន ដូចជា បញ្ហាតុលាការ ការអប់រំ យុវជនចំណាកស្រុក យុវជនជាកម្មករកាត់ដេរ និងបញ្ហាប្រាក់ខែតិចជាដើម។ គណបក្សសិទ្ធិមនុស្សបានលើកគោលនយោបាយសម្រាប់ពលរដ្ឋ ដោយផ្តល់ឥណទានដល់យុវជនក្នុងការបន្តការសិក្សា។ យុទ្ធនាការឃោសនារបស់គណបក្សប្រឆាំងធំជាងគេមួយនេះ ក៏ត្រូវបានហែហមដោយក្រុមយុវជនយ៉ាងច្រើនបន្តពីគណបក្សកំពុងកាន់អំណាចផងដែរ។ គណបក្សនយោបាយដទៃដែលចូលរួមប្រជែងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-

សង្កាត់ឆ្នាំ២០១២ ក៏បានឆ្លៀតគៀងគររកអ្នកគាំទ្រជាយុវជននៅគ្រប់ទីកន្លែងដែលជាក្រុមគោលដៅ និងសេសសល់ពីគណបក្សផ្សេងដើម្បីបង្គួតពីកម្លាំងគាំទ្ររបស់ខ្លួនជាយុវជនដូចគ្នា។

យុវជនមានការចាប់អារម្មណ៍ជាងមនុស្សចាស់ទាក់ទិននឹងព័ត៌មានបោះឆ្នោត ហើយយុវជនក៏ជួបឧបសគ្គក្នុងការបោះឆ្នោតច្រើនជាងមនុស្សចាស់ដែរ។ យោងតាមការសិក្សាស្រាវជ្រាវអ្នកមិនបានទៅបោះឆ្នោតរបស់ខុមហ្វ្រែលនៅបន្ទាប់ពីការបោះឆ្នោតក្នុង ចំណោមអ្នកមានសិទ្ធិបោះឆ្នោត ២,៥៣៦នាក់ ដែលក្នុងនោះមានយុវជន ៤៩.១% បានរកឃើញថាមិនបានទៅបោះឆ្នោត។ ការសិក្សាក៏បានរកឃើញដែរថាក្នុងចំណោមយុវជនដែលមិនបានបោះឆ្នោតនោះ មាន ៤៦.២១% បានទៅបោះឆ្នោត ប៉ុន្តែជួបឧបសគ្គ ដោយភាគច្រើនរកឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញ និងគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ សម្រាប់ប្រើក្នុងការបោះឆ្នោត។ ៤១.៧២% មានបំណងចង់ទៅបោះឆ្នោតប៉ុន្តែមិនបានទៅ ដោយភាគច្រើនមិនបានទៅចុះឈ្មោះបោះឆ្នោត។ ១២.០៦% មិនចង់ទៅបោះឆ្នោត ដោយភាគច្រើនលើកឡើងថាខ្ជិល ជាប់រវល់ការងារ/ការសិក្សា និងមិនដឹងថាទៅបោះឆ្នោតដើម្បីអ្វីជាដើម។ នេះជាបញ្ហាដែលនៅតែជាកត្តាប្រឈមធ្វើឲ្យបាត់បង់សិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត ជ្រើសរើសអ្នកដឹកនាំ ដែលផ្តើមចេញពីគំនិតរបស់យុវជន។

លទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់របស់គណកម្មាធិការរៀបចំការបោះឆ្នោត (គ.ជ.ប) ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ ខុមហ្វ្រែល រកឃើញថា យុវជនដែលមានអាយុចន្លោះពី២៥ ដល់៣៥ឆ្នាំ បានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន ៦១៥នាក់ (ស្ត្រី ២៩៣នាក់) ស្មើនឹង៥%នៃចំនួនក្រុមប្រឹក្សាឃុំ-សង្កាត់សរុបចំនួន ១១,៤៥៩នាក់ ភាគច្រើនជាយុវជននៅតាមបណ្តាខេត្ត និងដោយឡែកយុវជនជាប់ជាក្រុមប្រឹក្សាឃុំ-សង្កាត់នៅរាជធានីភ្នំពេញមាន៤៤នាក់ ឬ ៦.៩៩% នៃចំនួនក្រុមប្រឹក្សាសរុប។ តួលេខខាងលើនេះបើយើងសិក្សាអំពីចំនួនយុវជនដែលបានជាប់ជាក្រុមប្រឹក្សាឃុំ-សង្កាត់ តាមគណបក្សនយោបាយនីមួយៗ នៃចំនួនយុវជនសរុបដែលបានជាប់ជាក្រុមប្រឹក្សាឃុំចំនួន ៦១៥នាក់ យើងសង្កេតឃើញថាគណបក្សប្រជាជនមានយុវជនជាប់ជាក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន៤២៣នាក់ ស្មើ៣.៦៩% ដែលក្នុងនោះ១៦នាក់បានជាប់ជាមេឃុំ-សង្កាត់ (ស្ត្រី៧នាក់) គណបក្សសមរង្ស៊ីចំនួន១៤៥នាក់ ស្មើ១.២៦% ដែលក្នុងនោះ២នាក់ជាមេឃុំ-សង្កាត់ (ស្ត្រី១នាក់) គណបក្សសិទ្ធិមនុស្ស៣៩នាក់ជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ស្មើ ០.៣៤% គណបក្សហ៊្វុនស៊ិនប៉ិច៤នាក់ជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ស្មើ០.០៣% គណបក្សនរោត្តមរណឫទ្ធិមានតែ១នាក់ជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យមានចំនួន ៣នាក់ជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ស្មើ០.០២%។ គួរបញ្ជាក់ដែលថានៅក្នុងឆ្នាំ២០០៧ មានក្រុមប្រឹក្សាឃុំ សង្កាត់ជាយុវជន (អាយុក្រោម ៣០ឆ្នាំ) តែចំនួន ១៦៣នាក់ប៉ុណ្ណោះបានជាប់ឆ្នោត ដែលស្មើនឹង ១.៤៣% នៃចំនួនក្រុមប្រឹក្សាសរុប ១១,៣៥៣នាក់។ ក្នុងរយៈកាលកន្លងមកនៅមិនទាន់មានអ្នកតំណាងរាស្ត្រជាយុវជនទេ។

គួររំលឹកផងដែរថានៅក្នុងដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី២កន្លងមកខុមហ្វ្រែលបានពង្រាយអ្នកសង្កេតការណ៍ជាយុវជន ៦៧% នៃចំនួនអ្នកសង្កេតការណ៍សរុបជាង ៦ពាន់នាក់ ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) មានយុវជនចំនួន ៧០០នាក់ ចូលរួមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងអប់រំអ្នកបោះឆ្នោតជាពិសេសយុវជន និកហ្វិចបានពង្រាយអ្នកសង្កេតការណ៍ ៧៥%ជាយុវជន ក្នុងចំណោមអ្នកសង្កេតការណ៍សរុបជាង ៤ពាន់នាក់ និងសមាគមយុវជនខ្មែរ (KYA) មានអ្នកសង្កេតការណ៍ ៩០% ជាយុវជន។

ដោយឡែកសម្រាប់ការបោះឆ្នោតអាណត្តិទី៣ ឆ្នាំ២០១២កន្លងទៅថ្មីៗនេះ ខុមហ្វ្រែល បានពង្រាយអ្នកសង្កេតការណ៍ ៥,៦០២នាក់ ដែលក្នុងនោះអ្នកសង្កេតការណ៍ស្ម័គ្រចិត្តពីអង្គការ សមាគមនានា ភាគច្រើនគឺជាយុវជនដូចជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្តពី KYA (៤៥៦នាក់) KYSD (៣២៦នាក់) និងYRDP (៤៤នាក់)។ ជាមួយគ្នានេះកម្មវិធី Loy9 ក៏បានបង្កើតកម្មវិធីផ្សព្វផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍.ដែលលើកកម្ពស់ចំណេះដឹងទាក់ទងទៅនឹងការចុះឈ្មោះបោះឆ្នោតផងដែរ។ អង្គការ IRI បានរៀបចំកិច្ចពិភាក្សាយុវជននៃគណបក្សនយោបាយសំខាន់ៗ និងបើកវគ្គបណ្តុះបណ្តាលដល់សកម្មជនជាយុវជនមកពីគណបក្សនយោបាយនានា។ អង្គការយុវជនមួយចំនួនដូចជា ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) មានយុវជនចំនួន ៦៧៥នាក់ ចូលរួមក្នុងការលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការបោះឆ្នោតតាម រយៈកម្មវិធីវិទ្យុ ការប្រកួតប្រជែងការផ្ញើសារ កំប្លែង និងការបិទបញ្ជីឈ្មោះបោះឆ្នោត។

ជាសរុប បើទោះបីជាយុវជនមានសមត្ថភាព និងបញ្ចប់ការសិក្សាបរិញ្ញាបត្រក្នុងជំនាញបច្ចេកវិទ្យាថ្មីៗ តែការចូលរួមក្នុងនយោបាយ នៅតែត្រូវការកម្មវិធីអប់រំបន្ថែមទៀត។ យុវជនដែលជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីជួយបម្រើកិច្ចការរដ្ឋបាលមូលដ្ឋាន គឺនៅមានចំនួនតិចតួចនៅឡើយ។ យុវជនត្រូវបានគេ លើកទឹកចិត្ត ដោយគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិល ដើម្បីបានចូលរួមក្នុងការងារនយោបាយ និងបោះឆ្នោត ប៉ុន្តែតួនាទីរបស់យុវជននៅមានកម្រិតក្នុងការបម្រើកិច្ចការនយោបាយនៅឡើយ។ ចលនាយុវជនរបស់គណបក្សនយោបាយមិនទាន់មានរចនាសម្ព័ន្ធ និងគោលនយោបាយជាក់លាក់ និងមិនទាន់មានលទ្ធភាពក្នុងការដាក់ឥទ្ធិពលទៅលើការសម្រេចចិត្តរបស់គណបក្សនយោបាយទេ។ យុវជនបានចេញទៅបោះឆ្នោតក្នុងឆ្នាំ២០១២ អាចមានចំនួនតិចជាង ៦៥% ព្រោះពួកគេបានជួបឧបសគ្គច្រើន។ ការបន្តជម្រុញ និងលើកកម្ពស់ឲ្យយុវជនឲ្យមានការយល់ដឹងផ្នែកនយោបាយជារឿងសំខាន់ ហើយការ បណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មានតាមបច្ចេកវិទ្យាទំនើបៗនាសម័យថ្មីនេះ ដើម្បីលើកកម្ពស់ចំណេះដឹងរបស់យុវជនអំពីសារៈសំខាន់នៃការបោះឆ្នោតរឹតតែមានសារៈសំខាន់ថែមទៀត។ ជាមួយគ្នានេះ ភាគីពាក់ព័ន្ធជាពិសេសគណបក្សនយោបាយត្រូវ បង្ករឲ្យមានបរិយាកាសងាយស្រួលឲ្យយុវជនបានចូលរួមក្នុងវិស័យនយោបាយឲ្យកាន់តែទូលំទូលាយ ដោយហេតុថាពួកគេនឹង ក្លាយជាអ្នកដឹងនាំជំនាន់ក្រោយ និងជាដៃគូរដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់នូវការអភិវឌ្ឍន៍ជាតិ៕